## សម្រង់សារព័ត៌មានថ្ងៃទី១២-១៣-១៤ ខែសីហា ឆ្នាំ២០១៧

### ១.គេហទំព័រ The Phnom Penh Post

### *Apsara Authority continues removing homes in Angkor*

Mon, 14 August 2017 Soth Koemsoeun The Phnom Penh Post



The Apsara Authority and Siem Reap provincial officials have demolished 49 homes out of 520 slated for removal within the Angkor Archaeological Park since Thursday, officials said yesterday.

According to authority spokesman Long Kosal, the homes were mostly built during the 2017 commune elections season, with contractors "taking advantage" of the uncertainty to push schemes on clients.

"Apsara Authority usually sends its officials to explain [to the contractors] regularly, but they did not listen and neither did [the home buyers], who also believed in the lies of constructors," he said.

Read more: 'Illegal' Angkor homes dismantled in Siem Reap

According to Kosal the removals are starting in Prasat Bakong, Angkor Thom and Siem Reap districts, and will then proceed to Puok and Banteay Srei districts. Homes dating back to the 1980s, he said, will be unaffected.

However, some locals say small homes are being unfairly targeted.

"How about the hotel and huge housing compound that are in my area as well?" said Pich Sruoch, a villager in Nokor Thom commune whose home was destroyed.

### ២.គេហទំព័រ ភ្នំពេញប៉ុស្តិ៍

### *អាជ្ញាធរអប្សរាបន្តរុះរើសំណង់ខុសច្បាប់បាន ៤៩ កន្លែង*

Mon, 14 August 2017 សុទ្ធ គឹមសឿន (ភ្នំពេញប៉ុស្តិ៍)

ភ្នំពេញ: សំណង់ចំនួន ៤៩ កន្លែងក្នុងចំណោមសរុប ៥២០ កន្លែងដែលបានសាងសង់រំលោភលើដីរមណីយដ្ឋានអង្គរវត្តបានរុះរើរួចក្នុងរយៈពេលបីថ្ងៃដែលកម្លាំង អាជ្ញាធរអប្សរា និងសមត្ថកិច្ចចម្រុះនៃគណៈបញ្ជាការឯកភាពខេត្តសៀមរាបបានបើកប្រតិបត្តិការកាលពីសប្តាហ៍មុន ហើយក្នុងប្រតិបត្តិការនេះមិនទាន់មានការប្រឈមមុខដាក់គ្នារវាងអាជ្ញាធរ និងប្រជាពលរដ្ឋជាម្ចាស់សំណង់នោះទេ។



កាលពីថ្ងៃទី១ ខែសីហា អាជ្ញាធរអប្សរាបានចេញសេចក្តីជូនដំណឹងឲ្យប្រជាពលរដ្ឋដែលជាម្ចាស់សំណង់ធ្វើការរុះរើដោយខ្លួនឯង ហើយមានប្រជាពលរដ្ឋមួយចំនួនបានស្ម័គ្រចិត្តរុះរើដោយខ្លួនឯង និងមួយចំនួនទៀតមិនទាន់រុះរើតាមការជូនដំណឹងទើបរដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរអប្សរាចុះមករុះរើដោយផ្ទាល់ជាមួយនឹងកម្លាំងសមត្ថកិច្ចជាច្រើននាក់ និងរថយន្តបាញ់ទឹក និងរថយន្តសារ៉ែនជាច្រើនគ្រឿងផងដែរ។

លោក ឡុង កុសល់ ប្រធាននាយកដ្ឋានផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរាបានឲ្យដឹងកាលពីម្សិលមិញថា សំណង់បានសាងសង់រំលោភលើដីរមណីយដ្ឋានអង្គរវត្តក្នុងអំឡុងពេលមុន និងក្រោយពេលនៃយុទ្ធនាការបោះឆ្នោតសរុបចំនួន ៥២០ កន្លែងក្នុងនោះអាជ្ញាធរបានរុះរើផ្ទះ និងសំណង់ខុសច្បាប់បាន ៤៩ កន្លែង និងពលរដ្ឋបានស្ម័គ្រចិត្តរុះរើដោយខ្លួនឯងមានចំនួនប្រហែលជិត ៥០ កន្លែង ដោយគិតចាប់ពីថ្ងៃទី ១០ ដល់ ១៣ ខែសីហា។

លោកបន្តថាអាជ្ញាធរបានធ្វើការរុះរើសំណង់ខុសច្បាប់ទាំងនេះមាន ៣ គោលដៅធំៗរួមមានស្រុកប្រាសាទបាគង ស្រុកអង្គរធំ និងក្រុងសៀមរាប (មុខប្រាសាទបន្ទាយក្តី) ហើយ ២ គោលដៅទៀតនឹងបន្តនៅពេលក្រោយគឺនៅស្រុកពួក និងស្រុកប្រាសាទបន្ទាយស្រី។

លោកថា៖ «នេះគឺជាលេសរបស់ពួកគាត់ក្នុងការឆ្លៀតឱកាសអំឡុងពេលបោះឆ្នោតឆ្នាំ២០១៧-២០១៨ នេះ អាជ្ញាធរអប្សរាតែងតែបញ្ជូនមន្ត្រីរបស់ខ្លួនទៅនាំពួកគាត់ជាប្រចាំដែរ ប៉ុន្តែពួកគាត់មិនបានយកចិត្តទុកដាក់ព្រមទាំងបានជឿលើសម្តីភូតកុហករបស់ជាងផ្ទះ ឬជាងសំណង់មួយចំនួន។ អាជ្ញាធរអប្សរាមិនដែលប្រកាសថាកន្លែងនេះ ឬកន្លែងនោះអាចសាងសង់បាននោះទេ»។

លោកបញ្ជាក់ថាសំណង់ ឬផ្ទះដែលសង់ពីឆ្នាំ ១៩៨០ រហូតមកដល់ពេលនេះវាមិនមែនជាប្រធានបទនៃយុទ្ធនាការរុះរើនេះទេ។ កន្លងមកអ្នកសាងសង់ សំណង់ខុសច្បាប់ទាំងនេះភាគច្រើនពួកគាត់មិនមែនសាងសង់ក្នុងបំណងរស់នៅទេ ប៉ុន្តែពួកគាត់សាងសង់ក្នុងបំណងចាប់យកដី ឬចាប់យកទីតាំងទុកប្រើប្រាស់ផ្សេងៗទៀត និងមួយចំនួនជឿលើអ្នកញុះញង់ដូចជាអ្នកម៉ៅការសាងសង់សំណង់ ប៉ុន្តែអាជ្ញាធរមិនបានចូលរួមបិទបាំងនៃការសាងសង់ល្មើសច្បាប់នេះទេ។

លោក ពេជ្រ ស្រួច ប្រជាពលរដ្ឋនៅសង្កាត់នគរធំដែលរងនូវការរុះរើផ្ទះនេះបានប្រាប់កាលពីម្សិលមិញថា៖ «ខ្ញុំបាទគ្រាន់តែសាងសង់ផ្ទះនៅទេ មិនមែនធ្វើរឿងខុសច្បាប់អ្វីនោះទេ បើរើផ្ទះខ្ញុំ ខ្ញុំមិនដឹងទៅណាទៀតទេ។ បើនៅក្បែរប្រាសាទអង្គរទៅខ្ញុំមិនថាទេ តែនេះគឺឆ្ងាយដល់ទៅជិត ១០ គីឡូម៉ែត (តំបន់ ២)»។

លោក សូ ណារិន មន្ត្រីសម្របសម្រួលនៃអង្គការអាដហុកខេត្តសៀមរាបបានយល់ឃើញថា៖ «ការអនុវត្តរុះរើផ្ទះពលរដ្ឋនេះនៅមិនទាន់ស្មើភាពគ្នានៅឡើយទេ ដោយមិនបានអនុវត្តច្បាប់ព្រមគ្នា»។

ក្រុមគណៈកម្មការចម្រុះក៏អំពាវនាវដល់ប្រជាជនឲ្យស្ម័គ្រចិត្តក្នុងការរុះរើសំណង់ខុសច្បាប់ និងចូលរួមសហការជាមួយក្រុមការងារជាបន្តទៀតចៀសវាងការខូចខាតទ្រព្យសម្បត្តិ និងផលប្រយោជន៍របស់បងប្អូនទៀតផង៕

**៣.គេហទំព័រ** The CAMBODIA DAILY

*Villagers Ask for More Time to Remove Angkor Park Homes*

BY AUN PHEAP | AUGUST 14, 2017 The CAMBODIA DAILY

As an eviction operation inside Angkor Archaeological Park continues to plod forward, making modest progress after four days of remov als, some residents have now asked authorities to give them more time to tear down the structures themselves.

**៤.គេហទំព័រ** VOD

*ពលរដ្ឋរស់នៅក្នុងតំបន់អង្គរទាមទារឲ្យអាជ្ញាធរបញ្ឈប់ការរុះរើសំណង់ពួកគេ*

ដោយ លោក សូរ្យ ជ័យឧត្តម | ថ្ងៃចន្ទ ទី១៤ ខែសីហា ឆ្នាំ២០១៧ (VOD)



ប្រជាពលរដ្ឋប្រហែល ១០០នាក់ ដែលផ្ទះសម្បែងរបស់ពួកគេប្រឈមមុខនឹងការរុះរើនៅក្នុងតំបន់អភិរក្សអង្គរនោះ បានចេញតវ៉ានៅមុខសាលាខេត្តសៀមរាប នៅព្រឹកថ្ងៃនេះ ដោយទាមទារទៅអាជ្ញាធរខេត្តនេះ ឲ្យបញ្ឈប់ការរុះរើផ្ទះសម្បែងរបស់ពួកគេ។

អាជ្ញាធរខេត្តសៀមរាប កាលពីថ្ងៃទី០៩ ខែសីហានេះ បានជូនដំណឹងអំពីការចុះរុះរើសសំណង់នៅក្នុងតំបន់ ១ និងតំបន់ ២ ស្ថិតនៅក្នុងភូមិអញ្ច្រាញ សង្កាត់នគរធំ ក្រុងសៀមរាប ដោយថា សំណង់ទាំងនោះ ត្រូវបានសាងសង់ឡើងដោយខុសច្បាប់។

បន្ទាប់ពីការជូនដំណឹងនោះ ក្រុមអាជ្ញាធរខេត្តនេះ បានចាប់ផ្តើមចុះរុះរើសំណង់នានា ដូចដែលអាជ្ញាធរខេត្តនេះបានប្រកាសជាមុន។

ក្នុងដៃកាន់ទៅដោយរូបថតលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងភរិយាផងនោះ ក្រុមប្រជាពលរដ្ឋប្រហែល ១០០នាក់ បានប្រមូលផ្តុំគ្នានៅមុខសាលាខេត្តសៀមរាប នៅព្រឹកនេះ ដើម្បីទាមទារឲ្យបញ្ឈប់ការចុះរើរើសំណង់របស់ពួកគេ៕

**៥.គេហទំព័រ** RFI

*សំណង់មិនស្របច្បាប់នៅតំបន់អង្គរបានរុះរើចេញប្រមាណ ២៥% ហើយ*

14/08/2017 (RFI) អត្ថបទដោយ៖ តាន់ គឹមច័ន្ទវាសនា និងទី កញ្ញា



ក្រោយពីចំណាត់ការរបស់រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា ចុះរុះរើសំណង់នៅតំបន់អង្គររួចមក ប្រជាពលរដ្ឋមួយចំនួនបានស្ម័គ្រចិត្តរុះរើខ្លួនឯង ដើម្បីជៀសវាងការខូចខាត ទ្រព្យសម្បត្តិរបស់ខ្លួនធ្ងន់ធ្ងរ។ បើគិតចាប់ពីថ្ងៃម្សិលមិញ រហូតមកដល់ថ្ងៃ១៥សីហា សកម្មភាពរុះរើសំណង់ខុសច្បាប់ មានជាង ៦០ករណី ដែលជាការរុះរើរបស់កងកម្លាំងចំរុះ និង ៥០ទៅ ៥០ករណីផ្សេងទៀត គឺជាការស្ម័គ្រចិត្តរុះរើរបស់ប្រជាពលរដ្ឋ។

លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា បានបញ្ជាក់ប្រាប់វិទ្យុបារាំងថា ស្ថានភាពការរុះរើសំណង់មិនស្របច្បាប់ដំណើរការជាប្រក្រតី ដោយសារតែប្រជាពលរដ្ឋបានភ្ញាក់រលឹកក្នុងការរុះរើដោយខ្លួនឯង ដូច្នេះមិនចាំបាច់ប្រើប្រាស់កងកម្លាំងចំរុះចុះរុះរើនោះទេ តែប្រជាពលរដ្ឋអាចស្នើសុំកម្លាំងឲ្យជួយរុះរើបាន ដោយរក្សាទ្រព្យសម្បត្តិរបស់គាត់។ លោកបានឲ្យដឹងទៀតថា ចំពោះប្រជាពលរដ្ឋស្ម័គ្រចិត្តរុះរើដោយខ្លួនឯង អាជ្ញាធរអនុញ្ញាតអោយ ១ ទៅ២ ថ្ងៃបន្ថែមទៀត ក្នុងការរុះរើ។

អ្នកនាំពាក្យដដែលបានឲ្យដឹងថា សំណង់មិនស្របច្បាប់នៅក្នុងតំបន់អង្គរសរុបមានជាង៥០០សំណង់ ក្នុងនោះមានការរុះរើបានជិត១០០ករណី ស្មើប្រមាណ២៥% ដែលរួមបញ្ចូលទាំងការរុះរើដោយសមត្ថកិច្ចពាក់ព័ន្ធ និងការស្ម័គ្រចិត្ត។

ដោយឡែក អ្នកស្រី រិន សាដា ដែលជាប្រជាពលរដ្ឋសាងសង់ផ្ទះនៅភូមិរហាល បានត្អូញត្អែរថា អ្នកស្រីមិនអស់ចិត្តចំពោះចំណាត់ការរបស់អាជ្ញាធរនោះទេ ដោយអះអាងថា អ្នកស្រីនៅតែចង់តវ៉ា ដើម្បីអោយមានការដោះស្រាយតាមផ្លូវច្បាប់ ដោយហេតុថា មុននឹងអ្នកស្រីសាងសង់ផ្ទះអ្នកស្រីបានសុំការអនុញ្ញាតពីមេភូមិចាស់ តែការអនុញ្ញាតនេះមិនត្រូវបានទទួលស្គាល់ពីអាជ្ញាធរនោះទេ។

គួររំលឹកថា អាជ្ញាធរអប្សរា រួមនឹងរដ្ឋបាលខេត្តសៀមរាប បានជូនដំណឹងចំនួនពីរលើករួចមកដែលលើកទី១ ក្នុងខែកក្កដា ហើយលើកទី២ កាលពីថ្ងៃទី០១ ខែ សីហា ដល់ប្រជាពលរដ្ឋដែលបាននាំគ្នាទៅសាងសង់សំណង់ខុសច្បាប់នៅតំបន់ អង្គរកាលពីពេលកន្លងទៅ។ សេចក្តីជូនដំណឹងទាំងពីរលើកនោះ បានបញ្ជាឲ្យ រុះរើចេញដោយខ្លួនឯងមុននឹងចំណាត់ការចុងក្រោយដោយអាជ្ញាធរនៅថ្ងៃទី១០ ខែសីហានេះ។

**៦.គេហទំព័រ** Fresh news

***១.លទ្ធផលថ្ងៃទី២ នៃការរុះរើសំណង់ខុសច្បាប់ នៅរមណីយដ្ឋានអង្គរ, សំណង់ខុសច្បាប់ចំនួន២០ទីតាំង ក្នុងក្រុង-ស្រុកចំនួន៤ ត្រូវបានរុះរើរួចរាល់ ខណៈប្រជាពលរដ្ឋគ្មានការតវ៉ា (Video inside)***

Fresh news 12/08/2017



(សៀមរាប)៖ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧នេះ គឺជាថ្ងៃទី២ ហើយ នៃយុទ្ធនាការរុះរើសំណង់ខុសច្បាប់ ក្នុងតំបន់១ និងតំបន់២ នៃរមណីយដ្ឋានអង្គរ ជាលទ្ធផលកម្លាំងប្រតិបត្តិការបានរុះរើសំណង់ខុសច្បាប់ចំនួន២០ទីតាំង ក្នុងក្រុង-ស្រុកចំនួន៤ ខណៈដែលលទ្ធផលបានប្រព្រឹត្តទៅល្អប្រសើរ ដោយគ្មានការតវ៉ា ការប្រទូស្តរាយ និងគ្មានអំពើហិង្សាណាមួយកើតឡើង រវាងកងកម្លាំង និងម្ចាស់ទីតាំងសំណង់ខុសច្បាប់ទាំងនោះទេ។

អភិបាលរងខេត្តសៀមរាប លោក លី សំរិទ្ធិ បានបញ្ជាក់ថា សំណង់ខុសច្បាប់ចំនួន២០កន្លែង ដែលសមត្ថកិច្ចរុះរើនៅថ្ងៃនេះរួមមាន៖ ក្រុងសៀមរាប ចំនួន១៣សំណង់, ស្រុកប្រាសាទបាគង ចំនួន២សំណង់, ស្រុកអង្គរធំ ចំនួន៣សំណង់ ដោយឡែកនៅស្រុកបន្ទាយស្រី ត្រូវបានប្រជាពលរដ្ឋស្ម័គ្រចិត្តធ្វើកិច្ចសន្យារុះរើដោយខ្លួនឯង មុនកាលបរិច្ឆេទកំណត់នៅថ្ងៃទី១៤ ខែសីហាខាងមុខ គឺមានចំនួន២១សំណង់ តែរើរួចរាល់នៅថ្ងៃនេះ បាន២កន្លែង។

បើតាមអភិបាលរងខេត្តរូបនេះ «សម្រាប់ដំណើរការការងារថ្ងៃនេះ គណៈកម្មការដឹកនាំ និងសម្របសម្រួលបានវាយតម្លៃ និងសន្និដ្ឋានពីស្ថានភាពទូទៅប្រព្រឹត្តដោយល្អប្រសើរ គ្មានការទាមទារតវ៉ាពីប្រជាពលរដ្ឋ គ្មានការប្រទូស្តរាយដោយអំពើហិង្សាណាមួយ និងគ្មានអន្តរាគមន៍ពីកម្លាំងប្រដាប់អាវុធ នៃគណៈបញ្ជាការឯកភាពខេត្ត ដូចថ្ងៃម្សិលមិញនោះទេ»។

លោកបញ្ជាក់ថា មូលហេតុដែលនាំឲ្យស្ថានភាពរុះរើសំណង់ខុសច្បាប់ទាំងនេះ ប្រព្រឹត្តទៅដោយរលូននោះ ក៏ព្រោះតែម្ចាស់សំណង់បានភ្ញាក់រលឹក និងស្ម័គ្រចិត្តដល់កិច្ចសហការពេញលេញ ជាមួយក្រុមប្រតិបត្តិការគ្រប់មុខសញ្ញាទាំង៤កន្លែង តាមរយៈការខិតខំប្រឹងប្រែងចលនាអប់រំ ផ្សព្វផ្សាយពីច្បាប់ពីគោលនយោបាយ និងវិធានផ្សេងៗទៀត ក្នុងបរិបទនៃការអភិរក្ស ថែរក្សាសម្បត្តិបេតិកភ័ណ្ឌជាតិ និងពិភពលោក។

ជាមួយគ្នានេះ ក្រុមគណៈកម្មការចម្រុះ នៅតែអំពាវនាវដល់ប្រជាជនសូមឱ្យស្ម័គ្រចិត្ត ក្នុងការរុះរើសំណង់ខុសច្បាប់ និងចូលរួមសហការជាមួយ ក្រុមការងារជាបន្តទៀត ចៀសវាងការខូចខាតទ្រព្យសម្បត្តិ និងផលប្រយោជន៍ របស់បងប្អូនធូន់ធូរ។

ការអនុវត្តតាមច្បាប់នេះ គឺដើម្បីរួមគ្នាការពាររមណីយដ្ឋានអង្គរ ឱ្យមានភាពស្រស់ស្អាត រក្សាបាននូវទីតាំងប្រវត្តិសាស្ត្រ ដែលជាមរតកជាតិ ដ៏សំខាន់សម្រាប់កូនខ្មែរគ្រប់រូប គ្រប់ជំនាន់ឱ្យស្ថិតស្ថេរចីរកាល៕

***២.អភិបាលខេត្តសៀមរាប៖ ថ្ងៃទី៣នៃការរុះរើសំណង់ខុសច្បាប់ សមត្ថកិច្ចចម្រុះរុះរើបាន៣០សំណង់ ក្នុងក្រុង-ស្រុកចំនួន៣***

Fresh news 13/08/2017



(សៀមរាប)៖ នៅថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៧នេះ គឺជាថ្ងៃទី៣ហើយ នៃយុទ្ធនាការរុះរើសំណង់ខុសច្បាប់ ក្នុងតំបន់១ និងតំបន់២ នៃរមណីយដ្ឋានអង្គរ ជាលទ្ធផលកម្លាំងប្រតិបត្តិការ បានរុះរើសំណង់ខុសច្បាប់ចំនួន៣០ទីតាំង ក្នុងក្រុង-ស្រុកចំនួន៣ ខណៈដែលលទ្ធផលបានប្រព្រឹត្តទៅល្អប្រសើរ ដោយគ្មានការតវ៉ាការប្រទូស្តរាយ និងគ្មានអំពើហិង្សាណាមួយកើតឡើង រវាងកងកម្លាំង និងម្ចាស់ទីតាំងសំណង់ខុសច្បាប់ទាំងនោះទេ។

តាមរបាយការណ៍របស់ លោក ឃឹម ប៊ុនសុង ដែលអង្គភាពព័ត៌មាន Fresh News ទទួលបាន បញ្ជាក់ថា «លទ្ធផលសរុបថ្ងៃនេះ បានចំនួន៣០សំណង់ រួមមាន៖ ក្រុងសៀមរាប៩សំណង់ ក្នុងនោះស្ម័គ្រចិត្តរុះរើដោយខ្លួនឯង៦សំណង់, ស្រុកប្រាសាទបាគង ៨សំណង់ ដោយស្ម័គ្រចិត្តរុះរើដោយខ្លួនឯងទាំងអស់ និងស្រុកបន្ទាយស្រី ១៣សំណង់ ដោយស្ម័គ្រចិត្តរុះរើដោយខ្លួនឯងទាំងអស់»។

បើតាមអភិបាលខេត្តសៀមរាប សម្រាប់ដំណើរការការងារថ្ងៃនេះ គណៈកម្មការបានសម្របសម្រួល បានធ្វើការវាយតម្លៃ និងសន្និដ្ឋានថា ស្ថានភាពទូទៅបានប្រព្រឹត្តទៅល្អប្រសើរ គ្មានការទាមទារ តវ៉ាពីបងប្អូនប្រជាពលរដ្ឋឡើយ។

ជាមួយគ្នានេះ ក្រុមគណៈកម្មការចម្រុះ នៅតែអំពាវនាវដល់ប្រជាជនសូមឱ្យស្ម័គ្រចិត្ត ក្នុងការរុះរើសំណង់ខុសច្បាប់ និងចូលរួមសហការជាមួយ ក្រុមការងារជាបន្តទៀត ចៀសវាងការខូចខាតទ្រព្យសម្បត្តិ និងផលប្រយោជន៍ របស់បងប្អូនធូន់ធូរ។

ការអនុវត្តតាមច្បាប់នេះ គឺដើម្បីរួមគ្នាការពាររមណីយដ្ឋានអង្គរ ឱ្យមានភាពស្រស់ស្អាត រក្សាបាននូវទីតាំងប្រវត្តិសាស្ត្រ ដែលជាមរតកជាតិ ដ៏សំខាន់សម្រាប់កូនខ្មែរគ្រប់រូប គ្រប់ជំនាន់ឱ្យស្ថិតស្ថេរចីរកាល៕

**៧.គេហទំព័រ** CEN

### *១.៤ថ្ងៃ នៃយុទ្ធនាការរុះរើ សំណង់ខុសច្បាប់ ក្នុងឧទ្យានអង្គរមានសំណង់ ១០៩ករណី ត្រូវបានក្រុមការងាររុះរើ និងម្ចាស់សំណង់ ស្ម័គ្រចិត្តរុះរើខ្លួនឯង*

(ថ្ងៃទី 14 សីហា 2017, ម៉ោង 03:36:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(CEN)

សៀមរាប៖ បើគិតមកត្រឹមថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ គឺរយៈពេល ៤ថ្ងៃ ហើយនៃយុទ្ធនាការរុះរើសំណង់ខុសច្បាប់ក្នុងឧទ្យានអង្គរ ដែលអនុវត្តដោយក្រុមគណៈកម្មការចម្រុះ រួមមានអាជ្ញាធរជាតិអប្សរា និងរដ្ឋបាលខេត្តសៀមរាប រួមទាំងស្ថាប័នពាក់ព័ន្ធ ។



លទ្ធផលការងារដែលទទួលបានពីគោលដៅមានៈ ក្រុងសៀមរាប ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង និងស្រុកអង្គរធំ គឺមានសំណង់ខុសច្បាប់ចំនួន ១០៩ ករណី ដែលក្នុងនោះ ៦៥ករណី ត្រូវបានរុះរើរួចរាល់ ជាស្ថាពរដោយក្រុម គណៈកម្មការចម្រុះ និង៤៤ករណី ម្ចាស់សំណង់ បានស្ម័គ្រចិត្តធ្វើកិច្ចសន្យា រុះរើដោយខ្លួនឯង តែនៅមិនទាន់រុះរើ រួចរាល់នៅឡើយ ។

ក្រុមគណៈកម្មការចម្រុះ នឹងបន្តកិច្ចការនេះរហូតបញ្ចប់ទៅតាមគម្រោង ហើយអំពាវនាវដល់ប្រជាជនឱ្យស្ម័គ្រចិត្ត ក្នុងការរុះរើសំណង់ខុសច្បាប់ និងចូលរួមសហការជាមួយ ក្រុមការងារជាបន្តទៀត ចៀសវាងការខូចខាតទ្រព្យសម្បត្តិ និងផលប្រយោជន៍ របស់បងប្អូនធូន់ធ្ងរ។ ការអនុវត្តតាមច្បាប់នេះ គឺដើម្បីរួមគ្នាការពាររមណីយដ្ឋានអង្គរឱ្យមានភាពស្រស់ស្អាត រក្សាបាននូវទីតាំងប្រវត្តិសាស្ត្រដែលជាមរតកជាតិ ដ៏សំខាន់សម្រាប់កូនខ្មែរគ្រប់រូប គ្រប់ជំនាន់ឱ្យស្ថិតស្ថេរចីរកាល៕

### *២.គណៈកម្មការចម្រុះ រុះរើសំណង់ខុសច្បាប់ ក្នុងឧទ្យានអង្គរៈ នៅថ្ងៃទីពីរ នៃការចុះរុះរើសំណង់ខុសច្បាប់ ប្រជាជនមួយចំនួនធំ ព្រមទទួលខុស និងស្ម័គ្រចិត្តរុះរើ ដោយខ្លួនឯង*

(ថ្ងៃទី 11 សីហា 2017, ម៉ោង 04:20:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(CEN)



សៀមរាប: នៅក្នុងយុទ្ធនាការរុះរើសំណង់ ខុសច្បាប់ ក្នុងឧទ្យានអង្គរ នៅថ្ងៃទីពីរ ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ក្រុមគណៈកម្មការចម្រុះ បានរាយការណ៍ថា ប្រជាជននៅក្នុងតំបន់ គោលដៅទាំង៤ មានក្រុងសៀមរាប ស្រុកអង្គរធំ ស្រុកបន្ទាយស្រី និងស្រុកប្រាសាទបាគង ភាគច្រើន ព្រមទទួលខុសចំពោះ ការលួចសាងសង់ និងស្ម័គ្រចិត្តរុះរើ ដោយខ្លួនឯង។

ចំពោះទិន្នន័យ ដែលប្រជាជនព្រមរុះរើដោយខ្លួនឯង សរុបត្រឹមព្រឹកម៉ោង១១.៣០នាទីថ្ងៃនេះ គឺបានចំនួនសរុប ៣១ ករណី ដោយនៅក្នុងនោះ ក្រុងសៀមរាប មាន៧ករណី ស្រុកប្រាសាទបាគង មាន ២ ករណី នៅស្រុកបន្ទាយស្រី មាន២០ករណី និងនៅស្រុកអង្គរធំ មាន២ករណី។

សូមបញ្ជាក់ដែរថា សំណង់ទាំងនោះ មានទាំងប្រភេទធុន់ និងសំណង់ស្រាល។

ក្រុមគណៈកម្មការចម្រុះ ក៏នៅតែអំពាវនាវ ដល់ប្រជាជន ឱ្យស្ម័គ្រចិត្ត ក្នុងការរុះរើសំណង់ខុសច្បាប់ និងចូលរួមសហការ ជាមួយក្រុមការងារជាបន្តទៀត ចៀសវាងការខូចខាតទ្រព្យសម្បត្តិ និងផលប្រយោជន៍ របស់បងប្អូនធូន់ធ្ងរ។

ការអនុវត្តតាមច្បាប់នេះ គឺដើម្បីរួមគ្នាការពារ រមណីយដ្ឋានអង្គរ ឱ្យមានភាពស្រស់ស្អាត រក្សាបាននូវទីតាំង ប្រវត្តិសាស្រ្ត ដែលជាមរតកជាតិ ដ៏សំខាន់សម្រាប់ កូនខ្មែរគ្រប់រូប គ្រប់ជំនាន់ឱ្យស្ថិតស្ថេរចីរកាល៕N/t

**៨.គេហទំព័រ កម្ពុជាថ្មី**

## *១.កម្មសិក្សាការី១០ប្រទេសបានបញ្ចប់វគ្គសិក្សារយៈពេលខ្លីនៅតាមការដ្ឋានអំពីប្រវត្តិសាស្រ្តខ្មែរនិងការស្រាវជ្រាវបុរាណវិទ្យានៅលើទឹកដីអង្គរ*

គ្រឿន វេត 14/08 /2017 09:25 AM (កម្ពុជាថ្មី)



សៀមរាប៖ អស់រយៈពេល១៥ថ្ងៃនៃកម្មសិក្សានៅតាមការដ្ឋានអំពីប្រវត្តិសាស្រ្តខ្មែរនិងកំណាយស្រាវជ្រាវបុរាណវិទ្យានៅប្រាសាទទន្លេស្ងួត ក្រុមសិក្ខាកាមជាតិ-អន្តរជាតិចំនួន១៥រូប មានកម្ពុជា សិង្ហបុរី អូស្រ្តាលី ឥណ្ឌា ភូមា ម៉ាឡេស៊ី អាមេរិក ឥណ្ឌូនេស៊ី វៀតណាម និងប្រទេសហ្វីលីពីន បានបញ្ចប់ទស្សនកិច្ចចុងក្រោយនៅសារមន្ទីរនរោត្តមសីហនុ-អង្គរ នារសៀលថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧។

គម្រោងកម្មសិក្សានេះ រៀបចំដោយអាជ្ញាធរជាតិអប្សរាសហការជាមួយវិទ្យាស្ថានស្រាវជ្រាវអាស៊ីភាគអាគ្នេយ៍នៃប្រទេសសិង្ហបុរី ដែលមានលោកបណ្ឌិត អ៊ា ដារិទ្ធ អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ និងលោកបណ្ឌិត Kyle Latinis ជាសហប្រធានតំណាងអាជ្ញាធរជាតិអប្សរានិងសិង្ហបុរី។

តាមការបញ្ជាក់ពីលោកបណ្ឌិត អ៊ា ដារិទ្ធ បានឱ្យដឹងថា កម្មសិក្សានេះធ្វើឡើងក្នុងគោលបំណងបណ្តុះបណ្តាលអ្នកស្រាវជ្រាវនៅអាស៊ីអាគ្នេយ៍ជាមួយប្រទេសសិង្ហបុរី អាមេរិក ឥណ្ឌា ជប៉ុន និងកូរ៉េ។ នេះជាគម្រោងទី៥ហើយដែលបានសហការគ្នារវាងកម្ពុជានិងសិង្ហបុរី ដែលលើកមុនមានធ្វើនៅជើងឯក ភ្នំពេញ ភ្នំគូលែន កោះកែរ និងប្រាសាទទន្លេស្ងួត។

លោកបណ្ឌិតបន្តទៀតថា ក្នុងរយៈពេល១៥ថ្ងៃ យើងបានបណ្តុះបណ្តាលដល់សិក្ខាកាមទាំងអស់លើផ្នែកវប្បធម៌និងប្រវត្តិសាស្រ្តខ្មែរ ដោយទស្សនកិច្ចតាមប្រាសាទនានាដូចជា សម្បូរព្រៃគុក ប្រាសាទក្នុងតំបន់អង្គរ និងការអភិរក្សប្រាសាទរបស់អាជ្ញាធរជាតិអប្សរា។ បន្ថែមពីនោះក៏បានទៅសិក្សានៅតាមសារមន្ទីរកុលាលភាជន៍ភូមិតានី មើលរចនាសម្ពន្ធសម័យអង្គរ រួមទាំងប្រាសាទដែលជាមន្ទីរពេទ្យនិងសាលាសំណាក់សម័យបុរាណ និងការសិក្សាស្វែងយល់អំពីការជួសជុលបំណែកថ្មភក់ វត្ថុធ្វើពីសំរិទ្ធិ និងទៅមើលផ្ទាល់អំពីការជួសជុលរូបចម្លាក់នៅសារមន្ទីរនរោត្តមសីហនុ-អង្គរផងដែរ។ ក្រៅពីការសិក្សាលើផ្នែកទ្រឹស្តី យើងក៏មានការអនុវត្តលើផ្នែកកំណាយស្រាវជ្រាវបុរាណវិទ្យាដោយផ្ទាល់នៅប្រាសាទទន្លេស្ងួតអតីតមន្ទីរពេទ្យមួយក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ទៀតផង ដែល

ទទួលបានលទ្ធផលដ៏ល្អប្រសើរ។ លទ្ធផលដែលរកឃើញទាំងនោះត្រូវបានយកទៅរក្សាទុកនៅសារមន្ទីរនរោត្តមសីហនុ-អង្គរ និងយកទៅធ្វើបទបង្ហាញនៅប្រទេសសិង្ហបុរីបន្តទៀត ចាប់ពីថ្ងៃទី១៣ដល់១៦សីហា ឆ្នាំ២០១៧។

លោកបណ្ឌិត Kyle Latinis ក៏បានលើកឡើងដែរថា គម្រោងនេះបានទទួលការឧបត្ថម្ភថវិការពីក្រសួងការបរទេសប្រទេសសិង្ហបុរីនិងអាជ្ញាធរជាតិអប្សរាបានរួមចំណែកក្នុងការចំណាយលើថវិការរបស់បុគ្គលិកខ្លួន និងសម្រួលដល់សំបុត្រចេញចូលអង្គររបស់សិក្ខាកាមអន្តរជាតិទាំងអស់។ គម្រោងនេះនឹងបន្តសហការស្រាវជ្រាវបន្តទៀត យើងរីករាយណាស់ដែលបានធ្វើការរួមគ្នានិងបានរកឃើញរូបទ្វារបាល រួមទាំងបំណែកព្រះពុទ្ធរូបជាច្រើនដែលជាភស្តុតាងដ៏ប្រសើរសម្រាប់ការសិក្សាបុរាណវិទ្យានិងប្រវត្តិសាស្ត្រខ្មែរ។ នេះក៏ជាគម្រោងអាទិភាពមួយដែរដោយផ្តល់ឱកាសដល់អ្នកស្រាវជ្រាវខ្មែរលើកគម្រោងស្រាវជ្រាវដោយខ្លួនឯង ហើយជាអ្នកដឹកនាំគម្រោងស្រាវជ្រាវជាអ្នកបង្រៀនកម្មសិក្សាការីបរទេសទាំងអស់ផង។

កញ្ញា Natalie Khoo និស្សិតបុរាណវិទ្យានៃសាកលវិទ្យាល័យ Cambridge ប្រទេសសិង្ហបុរីបានលើកឡើងថា វគ្គសិក្សានេះមានសារៈសំខាន់ណាស់បានផ្តល់ឱកាសឱ្យពួកយើងបានសិក្សាបុរាណវិទ្យាជាមួយអ្នកជំនាញកម្ពុជាជាច្រើន ហើយបានផ្លាស់ប្តូរចំណេះដឹងផ្នែកនេះជាមួយនិស្សិតអន្តរជាតិផ្សេងៗទៀត។ ចំណែកលោក Amir Husni និស្សិតវិទ្យាសាស្ត្រ ផ្នែកបុរាណវិទ្យាមកពីប្រទេសឥណ្ឌូនេស៊ី បានចាប់អារម្មណ៍ថា សម្រាប់ការសិក្សាផ្នែកបុរាណវិទ្យា យើងគួរសិក្សានៅប្រទេសកម្ពុជា ដោយសារទីនេះមានសំណល់នៃវត្ថុបុរាណនិងបុរាណដ្ឋានជាច្រើនសម្រាប់ការសិក្សាដ៏ល្អដល់យើង។ វគ្គសិក្សានេះបានផ្តល់ឱកាសឱ្យយើងបានសិក្សាពីប្រាសាទជាច្រើនក្នុងតំបន់អង្គរ និងប្រវត្តិសាស្ត្ររបស់ខ្មែរ ពិសេសបានសិក្សាពីការគូរផែនទី ការធ្វើកំណាយ ការជីកដី និងទទួលបានចំណេះវិជ្ជាជាច្រើនពីសាស្ត្រាចារ្យខ្មែរ៕

## *២.ក្រោយពីគណៈកម្មការ ចម្រុះរុះរើសំណង់ ខុសច្បាប់ក្នុងឧទ្យានអង្គរ៖ នៅថ្ងៃទីពីរនៃការចុះរុះរើសំណង់ខុសច្បាប់ ប្រជាជនមួយចំនួនធំ ព្រមទទួលខុស និងស្ម័គ្រចិត្តរុះរើដោយខ្លួនឯង*

គ្រឿន វេត 12/08/2017 10:17am(កម្ពុជាថ្មី)



សៀមរាប៖ នៅក្នុងយុទ្ធនាការរុះរើសំណង់ខុសច្បាប់ក្នុងឧទ្យានអង្គរ នៅថ្ងៃទីពីរត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ក្រុមគណៈកម្មការចម្រុះបានរាយការណ៍ថា ប្រជាជននៅក្នុងតំបន់គោលដៅទាំង៤ មានក្រុងសៀមរាប ស្រុកអង្គរធំ ស្រុកបន្ទាយស្រី និងស្រុកប្រាសាទបាគង ភាគច្រើនព្រមទទួលខុសចំពោះការលួចសាងសង់និងស្ម័គ្រចិត្តរុះរើដោយខ្លួនឯង។

ចំពោះទិន្នន័យដែលប្រជាជនព្រមរុះរើដោយខ្លួនឯងសរុបត្រឹមព្រឹកម៉ោង ១១៖៣០នាទី ថ្ងៃនេះគឺបានចំនួនសរុប ៣១ករណី ដោយនៅក្នុងនោះ ក្រុងសៀមរាបមាន៧ករណី ស្រុកប្រាសាទបាគងមាន ២ករណី នៅស្រុកបន្ទាយស្រីមាន ២០ករណី និងនៅស្រុកអង្គរធំមាន ២ករណី។

សូមបញ្ជាក់ដែរថា សំណង់ទាំងនោះមានទាំង ប្រភេទធ្ងន់ និងសំណង់ស្រាល ។

ក្រុមគណៈកម្មការចម្រុះ ក៏នៅតែអំពាវនាវដល់ ប្រជាជនឱ្យស្ម័គ្រចិត្ត ក្នុងការរុះរើសំណង់ខុសច្បាប់ និងចូលរួមសហការ ជាមួយក្រុមការងារជាបន្តទៀត ចៀសវាងការខូចខាតទ្រព្យសម្បត្តិនិងផលប្រយោជន៍ របស់បងប្អូនធ្ងន់ធ្ងរ ។ ការអនុវត្តតាមច្បាប់នេះ គឺដើម្បីរួមគ្នាការពាររមណីយដ្ឋានអង្គរឱ្យមានភាពស្រស់ស្អាត រក្សាបាននូវទីតាំងប្រវត្តិសាស្ត្រ ដែលជាមរតកជាតិដ៏សំខាន់ សម្រាប់កូនខ្មែរគ្រប់រូប គ្រប់ជំនាន់ឱ្យស្ថិតស្ថេរថេរកាល ៕

**៩.គេហទំព័រ ដើមអម្ពិល**

## *៤ថ្ងៃ នៃយុទ្ធនាការរុះរើ សំណង់ខុសច្បាប់ ក្នុងឧទ្យានអង្គរមានសំណង់ ១០៩ករណី ត្រូវបានក្រុមការងាររុះរើ និងម្ចាស់សំណង់ ស្ម័គ្រចិត្តរុះរើខ្លួនឯង*

ថ្ងៃច័ន្ទ, ១៤ សីហា ២០១៧ 14:18 ដោយ: ដើមអម្ពិល ID:039



សៀមរាប៖ បើគិតមកត្រឹមថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ គឺរយៈពេល ៤ថ្ងៃ ហើយនៃយុទ្ធនាការរុះរើ សំណង់ខុសច្បាប់ក្នុងឧទ្យានអង្គរ ដែលអនុវត្តដោយក្រុមគណៈកម្មការចម្រុះ រួមមានអាជ្ញាធរជាតិអប្សរា និងរដ្ឋបាលខេត្តសៀមរាប រួមទាំងស្ថាប័នពាក់ព័ន្ធ ។

លទ្ធផលការងារដែលទទួលបានពីគោលដៅមាន៖ ក្រុងសៀមរាប ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង និងស្រុកអង្គរធំ គឺមានសំណង់ខុសច្បាប់ចំនួន ១០៩ករណី ដែលក្នុងនោះ ៦៥ករណី ត្រូវបានរុះរើរួចរាល់ ជាស្ថាពរដោយក្រុម គណៈកម្មការចម្រុះ និង៤៤ករណីម្ចាស់សំណង់ បានស្ម័គ្រចិត្តធ្វើកិច្ចសន្យា រុះរើដោយខ្លួនឯង តែនៅមិនទាន់រុះរើរួចរាល់នៅឡើយ ។

ក្រុមគណៈកម្មការចម្រុះ នឹងបន្តកិច្ចការនេះរហូតបញ្ចប់ទៅតាមគម្រោង ហើយអំពាវនាវដល់ប្រជាជនឱ្យស្ម័គ្រចិត្ត ក្នុងការរុះរើសំណង់ខុសច្បាប់ និងចូលរួមសហការជាមួយ ក្រុមការងារជាបន្តទៀត ចៀសវាងការខូចខាតទ្រព្យសម្បត្តិ និងផលប្រយោជន៍ របស់បងប្អូនធ្ងន់ធ្ងរ។ ការអនុវត្តតាមច្បាប់នេះ គឺដើម្បីរួមគ្នាការពាររមណីយដ្ឋានអង្គរឱ្យមានភាពស្រស់ស្អាត រក្សាបាននូវទីតាំងប្រវត្តិសាស្ត្រដែលជាមរតកជាតិ ដ៏សំខាន់សម្រាប់កូនខ្មែរគ្រប់រូប គ្រប់ជំនាន់ឱ្យស្ថិតស្ថេរថេរកាល ៕